# Seasons for Growth

## Adult Program



## រដូវកាលសម្រាប់វឌ្ឍនាការ (Seasons for Growth) – កម្មវិធីសម្រាប់មនុស្សពេញវ័យ

Seasons for Growth ពង្រឹងសុខុមាលភាពខាងផ្លូវអារម្មណ៍ និងផ្លូវចិត្តរបស់មនុស្សពេញវ័យដែលកំពុងសម្របខ្លួនទៅនឹងបទពិសោធន៍នៃការផ្លាស់ប្តូរ ការបាត់បង់ និងសេចក្តីទុក្ខសោកនៅក្នុងជីវិតរបស់ពួកគេ។

### តើកម្មវិធី Seasons for Growth នេះសម្រាប់នរណាខ្លះ?

មនុស្សពេញវ័យ ដែលរងការប៉ះពាល់ ដោយការផ្លាស់ប្តូរ ការបាត់បង់ និងសេចក្តីទុក្ខសោក ដែលអាចកើតឡើងពីបទពិសោធន៍ ដូចជា៖

- ការបែកបាក់ក្រុមគ្រួសារ ឬការលែងលះគ្នា
- ការបាត់បង់នរណាម្នាក់ ឬរបស់អ្វីមួយដែលអ្នកស្រឡាញ់
- ការផ្លាស់ទីលំនៅ
- ជំងឺ
- ការផ្លាស់ប្តូរជីវិតការងារក្នុងរង្វង់គ្រួសារ
- បុគ្គលដែលជាប់គុក
- ផលប៉ះពាល់នៃគ្រោះមហន្តរាយធម្មជាតិ និងជំងឺកូវីដ 19 ។

### តើកម្មវិធីនេះដំណើរការយ៉ាងដូចម្តេច?

Seasons for Growth គឺជាកម្មវិធីមួយដែលមានលក្ខណៈជាក្រុមតូចៗ ដែលបញ្ចូលចិត្តវិជ្ជា ការអប់រំ និងការជួយគ្នាទៅវិញទៅមក នៅក្នុងវិធីសាស្ត្រសិក្សាមួយដែលផ្តោតលើបុគ្គល។ អ្នកចូលរួមសិក្សាឲ្យយល់ថា ការផ្លាស់ប្តូរ និងការបាត់បង់ គឺជាផ្នែកមួយនៃជីវិត ហើយថា មិនមែនតែពួកគេម្នាក់ឯងទេដែលត្រូវដោះស្រាយជាមួយនឹងផលប៉ះពាល់នៃបទពិសោធន៍ទាំងនេះ។ កម្មវិធីនេះមានគោលបំណងធ្វើឲ្យបទពិសោធន៍របស់អ្នកចូលរួមវិលត្រឡប់មកសភាពធម្មតាវិញ ហើយអាចបង្កើនកត្តាបង្ការ (រាប់ទាំង ការកសាងភាពធន់ក្នុងខ្លួន និងជំនាញសង្គម) ស្របពេលជាមួយគ្នានោះដែរក៏កាត់បន្ថយឲ្យនៅតិចបំផុតនូវកត្តាហានិភ័យមួយចំនួន (រាប់ទាំង ការនៅឯកោ) ដែលមានឥទ្ធិពលមកលើសុខភាព និងសុខុមាលភាពខាងផ្លូវចិត្ត។

### លទ្ធផល

Seasons for Growth ផ្តល់ជំនួយគាំទ្រសម្រាប់មនុស្សពេញវ័យដើម្បី៖

- **ស្វែងយល់**ពីរបៀបដែលមនុស្សផ្សេងៗឆ្លើយតបទៅនឹងការផ្លាស់ប្តូរ ការបាត់បង់ និងសេចក្តីទុក្ខសោក
- **យល់ថា** វាគឺជារឿងធម្មតាក្នុងការជួបប្រទះប្រតិកម្មចំពោះសេចក្តីទុក្ខសោកនានា
- **ស្វែងរក**វិធីសាស្ត្រថ្មីៗក្នុងការប្រឈមនឹងការផ្លាស់ប្តូរ ការបាត់បង់ និងសេចក្តីទុក្ខសោកក្នុងជីវិតរបស់ពួកគេ
- **កសាងជំនាញទំនាក់ទំនង** ការធ្វើការសម្រេចចិត្ត និងការដោះស្រាយបញ្ហា
- **ចូលរួម**ក្នុងបណ្តាញទ្រទ្រង់មិត្តភក្តិ និងមនុស្សពេញវ័យ
- **បញ្ចូល**ការរៀនសូត្រថ្មីៗរបស់ពួកគេទៅក្នុងទំនាក់ទំនងជាមួយគ្រួសារ មិត្តភក្តិ និងអ្នកដទៃ។

> “
> សេចក្តីទុក្ខសោកគឺដូចជាអ័ព្ទអញ្ចឹង៖ អ្នកមិនអាចមើលឃើញច្រើន ហើយអ្នកឆ្ងល់ថាតើមនុស្សម្នាអាចមើលឃើញអ្នកទេ។ Seasons for Growth ជួយជូតសម្អាតអ័ព្ទនោះចេញ។
>
> អ្នកចូលរួមជាមនុស្សពេញវ័យ, Seasons for Growth



MacKillop Seasons

## តើកម្មវិធីនេះត្រូវបានផ្តល់ជូនយ៉ាងដូចម្តេច?

"គ្រូកន" ដែលទទួលបានការបណ្តុះបណ្តាល សម្របសម្រួលប្រធានបទណាមួយ ឬប្រធានបទទាំងពីរដូចខាងក្រោម នៃកម្មវិធីរដូវកាលសម្រាប់វយវឌ្ឍនាការសម្រាប់មនុស្សពេញវ័យ (Seasons for Growth Adult Program)៖

**ការស្វែររករដូវកាលមានសេចក្តីទុក្ខសោក** ដែលត្រូវផ្តល់ជូនពី 4-8 វគ្គ គឺជាកម្មវិធីមួយសម្រាប់សេចក្តីទុក្ខសោក និងការបាត់បង់ដែលធ្វើឡើងជាលក្ខណៈក្រុមតូចៗ (អ្នកចូលរួម 4-7 នាក់)។

**ការយល់ដឹងអំពីការផ្លាស់ប្តូរ ការបាត់បង់ និងសេចក្តីទុក្ខសោ**ក គឺជាសិក្ខាសាលារយៈពេល 3 ម៉ោង ដែលត្រូវបានរៀបចំឡើងសម្រាប់ការប្រើប្រាស់ក្នុងបរិបថជាច្រើន ដែលមានអ្នកចូលរួមរហូតដល់ទៅ 25 នាក់ ដែលក្រុម និងបុគ្គលផ្សេងៗកំពុងស្វះស្វែងយល់ដឹងទូទៅ ឱ្យកាន់តែស៊ីជម្រៅ អំពីការផ្លាស់ប្តូរ ការបាត់បង់ និងសេចក្តីទុក្ខសោក។

គ្រូកនទាំងនោះ អាចជាបុគ្គលិករបស់ទីភ្នាក់ងារ អ្នកស្ម័គ្រចិត្តដែលគេផ្តល់សិទ្ធិ ឬមនុស្សពេញវ័យសមរម្យផ្សេងទៀត ដែលបានឆ្លងកាត់សិក្ខាសាលាបណ្តុះបណ្តាលរយៈពេលពីរថ្ងៃ។

## ភស្តុតាង និងការវាយតម្លៃ

ចាប់តាំងពីឆ្នាំ 1996 ការត្រួតពិនិត្យឡើងវិញ និងការវាយតម្លៃជាច្រើនបានបញ្ជាក់ថា កម្មវិធី Seasons for Growth ផ្តល់ជូនបទពិសោធន៍ជាវិជ្ជមានយ៉ាងលើសលប់ និងលទ្ធផលដែលមានប្រយោជន៍ដល់មជ្ឈដ្ឋានជាច្រើន។ ដោយឆ្លុះបញ្ចាំងពីកម្មវត្ថុនានានៃកម្មវិធីនេះ ការវាយតម្លៃជាច្រើននាពេលចុងក្រោយនេះ បានសន្និដ្ឋានថា កម្មវិធី Seasons for Growth៖

- **កសាង**ការយល់ដឹង និងជំនាញនានាដើម្បី គ្រប់គ្រងការផ្លាស់ប្តូរ ការបាត់បង់ និងសេចក្តីទុក្ខសោក។
- **ធ្វើឱ្យប្រសើរឡើងដល់**សុខុមាលភាពខាងផ្លូវអារម្មណ៍របស់អ្នកចូលរួម។
- **ផ្តល់លទ្ធភាពឱ្យ**អ្នកចូលរួមអាចបញ្ចេញទស្សនៈ គំនិត និងអារម្មណ៍របស់ពួកគេ។
- **ពង្រឹង**បណ្តាញសង្គម និងការទ្រទ្រង់របស់អ្នកចូលរួម។





> "
>
> អ្នកចូលរួមបានទទួលចំណេះដឹង ជំនាញ និងការយល់ដឹងកាន់តែកើនឡើង អំពីការផ្លាស់ប្តូរ ការបាត់បង់ និងសេចក្តីទុក្ខសោក ហើយទទួលបានឧបករណ៍នានា ដើម្បីជួយគ្រប់គ្រងបញ្ហា នាពេលបច្ចុប្បន្ន និងអតីតកាល។
>
> សមាគមសុខភាពផ្លូវចិត្តរដ្ឋ NSW

## ព័ត៌មានបន្ថែម

កម្មវិធីរដូវកាលសម្រាប់ការជាសះស្បើយ (Seasons for Healing Program) ផ្តល់ការជួយទ្រទ្រង់ដែលមានសុវត្ថិភាពខាងវប្បធម៌សម្រាប់អ្នកស្រុកដើម និងមនុស្សពេញវ័យមកពីកោះ Torres Strait ដែលផ្តល់ជូននូវវិធីសាស្ត្រអប់រំ វប្បធម៌ និងការព្យាបាលដើម្បីជួយឲ្យជាសះស្បើយពីការបាត់បង់ និងសេចក្តីទុក្ខសោក។

**តំណភ្ជាប់ដែលមានប្រយោជន៍៖**

បញ្ជីលេខទូរសព្ទជំនួយសម្រាប់ការរក្សាទឹកចិត្តឲ្យនៅរឹងប៉ឹង (Keeping Spirit Strong Support Directory) ជួយទ្រទ្រង់ដល់ក្រុមគ្រួសារ និងសហគមន៍របស់ជនជាតិដើមដំបូង ដែលជួបប្រទះនូវការបាត់បង់ និងសេចក្តីទុក្ខសោក។

**Seasons for Growth** កម្មវិធីសម្រាប់កុមារ និងក្មេងៗ (Children and Young People's Program)

## ទាក់ទងមកយើងខ្ញុំ

1300 379 569 | info.seasons@mackillop.org.au

MacKillop Seasons

mackillopseasons.org.au